**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីប្រកាសព័ត៌មាន

នៅព្រឹកថ្ងៃអង្គារ ៧ កើត ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១ ត្រូវនឹងថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៨ នៅសណ្ឋាគារសូហ្វីតែល ភូគីត្រា រាជធានីភ្នំពេញ **ឯកឧត្តមបណ្ឌិត អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានទទួលជួបពិភាក្សាការងារ ជាមួយ **ឯកឧត្តម Dato' Sri Richard Riot Anak Jaem** រដ្ឋមន្ត្រីក្រសួងធនធានមនុស្ស នៃប្រទេសម៉ាឡេស៊ី ដើម្បីពិភាក្សាកិច្ចសហប្រតិបត្តិការក្នុងការជំរុញ និងបង្កើនល្បឿននៃការអនុវត្តអនុស្សរណៈ នៃការយោគយល់គ្នារវាងរាជរដ្ឋាភិបាលនៃប្រទេសទាំងពីរ ស្តីពីការជ្រើសរើស ការបណ្តុះបណ្តាល ការបញ្ជូន និងការគ្រប់គ្រងពលករខ្មែរទៅធ្វើការនៅប្រទេសម៉ាឡេស៊ី ឱ្យបានឆាប់ ដើម្បីធានាដល់ការការពារសិទ្ធិ និងអត្ថប្រយោជន៍របស់ពលករកម្ពុជាទៅធ្វើការនៅប្រទេសម៉ាឡេស៊ី។

ក្នុងជំនួបនៃកិច្ចប្រជុំនេះ ភាគីទាំងពីរបានសម្តែងនូវការពេញចិត្តយ៉ាងខ្លាំងនូវលទ្ធផលដ៏ល្អនៃកិច្ចសហប្រតិបត្តិការនាពេលកន្លងមក។ ដើម្បីពង្រឹងប្រសិទ្ធភាពក្នុងការគ្រប់គ្រង និងការពារពលករកម្ពុជាដែលទៅធ្វើការនៅប្រទេសម៉ាឡេស៊ី ភាគីទាំងពីរ បានឯកភាពរៀបចំឱ្យមានមជ្ឈមណ្ឌលសម្រាប់អប់រំណែនាំតម្រង់ទិសពលករមុនចេញដំណើរទៅធ្វើការនៅប្រទេសម៉ាឡេស៊ី និងការចេញវិញ្ញាបនបត្របញ្ជាក់សមត្ថភាពដល់ពលករខ្មែរ ដែលបានបញ្ចប់វគ្គអប់រំណែនាំតម្រង់ទិសមុនចេញដំណើរដោយជោគជ័យ។ ទន្ទឹមនឹងនេះ ភាគីទាំងពីរក៏បានឯកភាពគ្នាបន្តកិច្ចប្រជុំថ្នាក់មន្ត្រីបច្ចេកទេសជាន់ខ្ពស់លើកទី៥ និងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីលើកទី៤ នាសប្តាហ៍ទី១ ខែកុម្ភៈ ឆ្នាំ២០១៨ ខាងមុខនេះ នៅប្រទេសម៉ាឡេស៊ី ដើម្បីបន្តធ្វើការពិភាក្សាលើបញ្ហាដែលសេសសល់ឱ្យចប់សព្វគ្រប់ ដែលអាចឱ្យដំណើរការចាប់ផ្តើមបញ្ជូនពលករខ្មែរទៅធ្វើការនៅប្រទេសម៉ាឡេស៊ីលើកដំបូង នាដើមខែមិថុនា ឆ្នាំ២០១៨ តទៅ។

*រាជធានីភ្នំពេញ ថ្ងៃអង្គារ ៧ កើត ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១*

*ថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៨*